FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ
ឆ្នាំទី ៣ លេខ ២២ ខែមីនា ឆ្នាំ ២០០៨
ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# វិធីទុកដាក់គ្រាប់ធញ្ញជាតិតាមលក្ខណៈគ្រួសារ

បន្ទាប់ពីច្រូតកាត់ និងបោកបែនហើយ គ្រាប់ធញ្ញជាតិតែងត្រូវបានគេរក្សាក្នុងបរិក្ខារទុកដាក់ផ្សេងៗ ដែលជាលក្ខណៈប្រពៃណីមានរយៈពេលពី ៦ ទៅ ១២ខែ។ ជាទូទៅ បរិក្ខារទុកដាក់ទាំងនោះមានលក្ខណៈសមស្របទៅនឹងលក្ខខណ្ឌសង្គម សេដ្ឋកិច្ច និងអាកាសធាតុ ហើយត្រូវបានគេសាងសង់វាឡើងដោយប្រើប្រាស់វត្ថុធាតុដើមដែលអាចរកបានក្នុងតំបន់។ ការទុកដាក់ផលិតផលនៅតាមកសិដ្ឋានតូចៗ អាចចែកជា ៣ប្រភេទ សំខាន់ៗគឺ ប្រព័ន្ធចំហ ពាក់កណ្តាលចំហ និងបិទជិត។

## ១. ប្រព័ន្ធចំហ

ក្នុងលក្ខខណ្ឌអាកាសធាតុមិនអំណោយផលល្អ (គឺមានសភាពក្តៅហើយសើម) គេតែងតែប្រើប្រាស់ប្រព័ន្ធទុកដាក់ប្រភេទចំហស្ទើរតែទាំងស្រុង ដោយសារថា ផលិតផលភាគច្រើននៅមានកំរិតសំណើមមិនទាន់សមស្របសំរាប់ទុកដាក់នៅឡើយ។ ជង្រុករបៀបនេះគេច្រើនធ្វើបាតកំរាលពីបន្ទះក្តារ ឬរនាបអោយផុតពីដីដែលទ្រដោយសសរហើយប្រក់ដំបូលផ្សេងៗគ្នាដូចជា: ចំបើង ស្លឹកត្នោត ឬស្បូវជាដើមដើម្បីការពារទឹកភ្លៀង។ ពេលខ្លះគេយកផលិតផលចំការផ្សេងៗដូចជា ផ្លែពោតទុំ រី ននោងទុំ ជាដើមទៅព្យួរតាមធ្នឹម ឬនៅពីក្រោមដំបូលផ្ទះបាយដើម្បីឱ្យផ្សែងភ្លើងដែលដុតពីក្រោមទៅធ្វើអោយផលិតផលនោះកាន់តែស្ងួត និងបណ្តេញសត្វល្អិតចេញបានទៀតផង ។

ជាទូទៅ សំណង់ប្រព័ន្ធទុកដាក់ចំហបែបនេះ ច្រើនតែមិនមានភាពស្មុគស្មាញ ប៉ុន្តែវាបង្កអោយមានការលំបាកក្នុងការសំអាត ឬ ធ្វើអនាម័យ។

### គុណសម្បត្តិ :

- ខ្យល់ធម្មជាតិដែលបក់ឆ្លងកាត់ នឹងធ្វើអោយផលិតផលដែលកំពុងទុកដាក់កាន់តែស្ងួតជាបន្ត
- សភាពបែបនេះក៏ទប់ស្កាត់ការកើតមាននូវជម្ងឺផ្សិតផងដែរ។

### គុណវិបត្តិ :

- សត្វល្អិត កណ្តុរ និងសត្វស្លាប អាចចេញចូលបានដោយងាយ និងពិបាកធ្វើអនាម័យ

## ២. ប្រព័ន្ធទុកដាក់ពាក់កណ្តាលចំហ

ប្រព័ន្ធបែបនេះត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយនៅតំបន់នានា ដែលមានភ្លៀងធ្លាក់មធ្យមហើយបរិក្ខារទុកដាក់ច្រើនធ្វើពីមែកឈើតូចៗឬចំបើងត្បាញឬវេញបញ្ចូលគ្នាក៏ដូចជាគ្រោងឈើដែលមានក្រាលចំបើង។ ជាទូទៅ គេច្រើនប្រើប្រាស់ប្រព័ន្ធនេះសំរាប់ទុកដាក់ផលិតផលដែលមិនទាន់បោកបែនឬប្រឡេះគ្រាប់។ ការដែលផលិតផលប៉ះផ្ទាល់ជាមួយដីបណ្តាលអោយផលិតផលនោះអាចស្រូបយកសំណើមពីដីថែមទៀត ប៉ុន្តែវាតែងតែត្រូវបានបង្ការដោយការដាក់តំកល់ពីក្រោមនៃបរិក្ខារទុកដាក់ខាងលើ។ ដំបូលធ្វើពីចំបើង ស្លឹក ឬ ស្បូវ ផ្តល់នូវការការពារផលិតផលមិនអោយត្រូវទឹកភ្លៀង ។



ប្រព័ន្ធទុកដាក់ពាក់កណ្តាលចំហផ្តល់នូវការការពារដល់ផលិតផល មិនអោយរងលក្ខខណ្ឌអាកាសធាតុបានល្អជាងប្រព័ន្ធទុកដាក់ចំហ ប៉ុន្តែវាធ្វើអោយមានខ្យល់បក់ឆ្លងកាត់ផលិតផលតិចជាងមុនហើយក៏មិនជាការលំបាកសំរាប់សត្វចង្រៃនានាចេញចូលដែរ។

## ៣. ប្រព័ន្ធទុកដាក់បិទ

នៅតំបន់នានាដែលស្ងួត ការទុកដាក់គ្រាប់ធញ្ញជាតិនានាភាគច្រើនគេប្រើប្រាស់បរិក្ខារទុកដាក់បិទជិត ដែលធ្វើអំពីដីឥដ្ឋ និងជួនកាលមានលាយចំបើងផង។ តាមធម្មតា ផលិតផលដែលទុកដាក់ ត្រូវបានគេប្រឡេះគ្រាប់ ឬ បោកបែនហើយ។ តាមរបៀបនេះ គេមិនមានបញ្ហាជាមួយសំណើម និងកំណជាញើសឡើយ ដោយសារតែផលិតផលមានអត្រាសំណើមទាប ហើយដីឥដ្ឋនោះអាចទប់ស្កាត់ការជ្រៀតសំណើមបានយ៉ាងល្អ។ គេផលិតបរិក្ខារទុកដាក់បែបនេះក្នុងទំរង់ និងទំហំជាច្រើនខុសៗគ្នា ដោយមានគំរបបិទបើក និងដំបូលប្រក់ពីលើ។ គេច្រើនយកថ្មធំៗទៅកល់ពីក្រោមវាដើម្បីទប់ស្កាត់ការឆ្លងសំណើមពីដីទៅផលិតផល។



ពាងធ្វើពីដីដុត ធុងធ្វើពីឈើ និងធុងសាំង រឺធុងប្លាស្ទិច ត្រូវបានគេប្រើប្រាស់ និងរកឃើញថា វាបានផ្តល់នូវលទ្ធផលយ៉ាងល្អសំរាប់ការទុកដាក់គ្រាប់ពូជ ឬគ្រាប់ធញ្ញជាតិធម្មតានៅតាមផ្ទះ (ត្រូវហាលសំងួតផលិតផលអោយស្ងួតល្អសិនមុននឹងទុកដាក់)។

ក្នុងប្រព័ន្ធទុកដាក់បិទជិត កំណជាញើសអាចនឹងកើតមានជាពិសេស នៅពេលដែលបរិក្ខារទុកដាក់ធ្វើពីលោហធាតុ (ធុងសាំង និងប្លាស្ទិច)។ ក្នុងករណីនេះគេត្រូវតែប្រុងប្រយ័ត្នដើម្បីរក្សាអោយសីតុណ្ហភាពក្នុងប្រព័ន្ធមានសភាពថេរ ដោយដាក់វានៅក្នុងម្លប់។

### គុណសម្បត្តិ :

- តាមធម្មតាវាទប់ស្កាត់បានល្អជាមួយនឹងការជ្រៀតចូលនៃសត្វល្អិត
- បរិយាកាសនៅខាងក្នុងបរិក្ខារធ្វើពីដីឥដ្ឋរបៀបនេះច្រើនមានសភាពត្រជាក់ និងស្ងួត
- បរិក្ខារបិទជិតទប់ស្កាត់បានមួយចំនួននូវការជ្រៀតចូលនៃខ្យល់ ហើយការដកដង្ហើមរបស់សត្វល្អិត និងផលិតផលតែងបង្កអោយមានកង្វះខាតអុកស៊ីសែនដែលធ្វើអោយសត្វល្អិតពុំអាចទ្រាំរស់នៅតទៅទៀតបាន។ បរិមាណអុកស៊ីហ្សែនដែលនៅសល់តិចតួច គឺគ្រប់គ្រាន់សំរាប់អោយគ្រាប់ពូជនៅតែរក្សាបាននូវថាមពលដំណុះគ្រាប់ ( ប្រព័ន្ធទុកដាក់បិទជិត ១00%)។

### គុណវិបត្តិ :

- សំណង់បរិក្ខារធ្វើពីដីឥដ្ឋមិនអាចទប់ស្កាត់នូវការជ្រាបទឹកបានទាំងស្រុងឡើយ។ វាងាយបែកប្រេះឬខូចខាតដែលទាមទារអោយត្រូវឧស្សាហ៍ជួសជុល ឬ ធ្វើវាឡើងវិញ ហើយស្នាមប្រេះនានាគឺជាជំរកដ៏ល្អរបស់សត្វល្អិត។
- កំណជាញើស គឺជាគ្រោះថ្នាក់ដ៏ធំ ជាពិសេសនៅពេលដែលបរិក្ខារត្រូវបានធ្វើឡើងពីលោហធាតុ។

### អត្រាសំណើមសុវត្ថិភាពសំរាប់ការទុកដាក់យូរ

កាលណាផលិតផលមានសភាពសើមខ្លាំង ឬ មានអត្រាសំណើមខ្ពស់ វាងាយរងការខូចខាតដោយការកើតជំងឺផ្សិត។ អត្រាសំណើមសុវត្ថិភាពមានកំរិតផ្សេងៗគ្នាទៅតាមប្រភេទនៃផលិតផល :

| ផលិតផល | អត្រាសំណើមសុវត្ថិភាព (%) | ផលិតផល | អត្រាសំណើមសុវត្ថិភាព (%) |
|---|---|---|---|
| ពោត | ១៣ | សណ្តែក | ១៥ |
| ស្រូវសាលី | ១៣ | សណ្តែកដី | ៧ |
| ស្រូវ | ១៤ | កាការ | ៧ |
| អង្ករ | ១៣ | កាហ្វេ | ១៣ |

លក្ខណ្ឌដ៏ល្អប្រសើរបំផុតសំរាប់ការកើតមានសត្វល្អិតគឺនៅសីតុណ្ហភាពពី ២៨ ទៅ ៣៣ អង្សាសេ និងសំណើមធៀបពី ៦0 ទៅ ៨0%។ ជាមួយនោះវាក៏បង្កើនចំនួនកូនចៅបានច្រើនណាស់ដែរ។

សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិស្វកម្មកសិកម្ម មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ,

ទូរស័ព្ទលេខ:(៨៥៥-២៣) ៦៣១៩ ៦៩៣-៤ ទូរអក្ខរ: **cardi@cardi.org.kh** វែបសាយ: **www.cardi.org.kh**

Sbunna@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh